# ស្ថានទូតអូស្ត្រាលី

# ភ្នំពេញ

## សេចក្តីប្រកាសពត៌មាន

## ដំណើរទស្សនៈកិច្ចនាវា HMAS BATHURST របស់កងទ័ពជើងទឹកភូមិន្ទអូស្ត្រាលី មកកាន់ខេត្តព្រះសីហនុ ប្រទេសកម្ពុជា

នាវាកងទ័ពជើងទឹកភូមិន្ទអូស្ត្រាលី ឈ្មោះ អេចអ៊ីមអេអេស បាហ្សឺស្ត៍ (HMAS BATHURST) នឹងមកបំពេញទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៩ ដល់ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៩ ។ ដំណើរទស្សនៈកិច្ចនេះនឹង ពង្រឹងចំណងទាក់ទងជិតស្និទ្ធរវាងប្រទេសកម្ពុជា និងប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការកងទ័ពរបស់អូស្ត្រាលី និងជាការបន្តដំណើរទស្សនៈកិច្ចប្រកបដោយជោគជ័យបន្ទាប់ពីដំណើរទស្សនៈកិច្ចរបស់នាវាកងទ័ពជើងទឹក អូស្ត្រាលីកាលពីឆ្នាំមុនៗមានដូចជា: HMAS Darwin មកដល់ក្នុងខែ កញ្ញា ឆ្នាំ ២០០៩ HMAS Bathurst នៅក្នុងខែ មេសា ឆ្នាំ ២០០៩ HMAS ADELAIDE នៅក្នុងខែ ឧសភា ឆ្នាំ ២០០៧ និងខែ សីហា ឆ្នាំ ២០០៥ HMAS TOOWOOMBA នៅក្នុងខែ មេសា ឆ្នាំ ២០០៦ HMAS DARWIN នៅក្នុងខែ តុលា ឆ្នាំ ២០០៤ HMAS GERALDON នៅក្នុងខែ កញ្ញា ឆ្នាំ ២០០៤ ព្រមទាំង HMAS GASCOYNE និង HMAS NORMAN នៅក្នុងខែ ឧសភា ឆ្នាំ ២០០៣ ។

ក្នុងកំឡុងពេលទស្សនៈកិច្ច មេបញ្ជាការនាវា HMAS BATHURST គឺលោកវរនាវីទោ ស្ទីវ តារ៉ាហ្គែល (Steve Taragel) នឹងជួបសំដែងការគួរសមចំពោះអភិបាលខេត្តព្រះសីហនុ គឺឯកឧត្តម ស្បោង សារ៉ាត់ និងមេបញ្ជាការ ដែនសមុទ្រ នៅមូលដ្ឋានរាម គឺឯកឧត្តម ឧត្តមនាវីទោ អ៊ុក សីហា ។

នាវា HMAS BATHURST គឺជានាវាល្បាតប្រភេទ Armidale Class Patrol Boat មួយ និងជានាវាចម្បាំងដែលមានសមត្ថភាពខ្ពស់ព្រមទាំងអាចបត់បែនក្នុងការប្រតិបត្តិការងារ និងបេសកកម្មបានមួយចំនួនធំ ។ ភារកិច្ចស្នូលមួយរបស់នាវានេះ គឺការរួមចំណែកដល់កម្មវិធីឈ្លបយកការណ៍ស៊ីវិលរបស់ប្រទេសអូស្ត្រាលី ។ ប្រតិបត្តិការរបស់នាវា HMAS BATHURST គឺទប់ស្កាត់មិនមានការចូលខុសច្បាប់ ការប្រព្រឹត្តល្មើសនឹងច្បាប់គយ

អន្តោប្រវេសន៍ខុសច្បាប់ ការរត់ពន្ធមនុស្ស និងពង្រឹងច្បាប់គ្រឿងញៀន ដោយរក្សាបាននូវបូរណភាពនៃធនធានមច្ឆាជាតិរបស់ប្រទេសអូស្ត្រាលី បរិស្ថានសមុទ្រ ព្រមទាំងធនធានធម្មជាតិផ្សេងៗទៀតផងដែរ ។

សំរាប់ពត៌មានបន្ថែម និងរូបថតរបស់នាវា HMAS BATHURST សូមរកមើលតាមវេបសាយ http://www.navy.gov.au ។

នឹងមានការផ្តល់ឱកាសសំរាប់ថតរូប និងជួបជាមួយបណ្តាញអ្នកយកពត៌មាននៅក្នុងខេត្តព្រះសីហនុ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៩ ។ បុគ្គលិកសារពត៌មានដែលចាប់អារម្មណ៍ក្នុងការចូលរួមក្នុងឱកាសទាំងនេះ សូមទំនាក់ទំនងចុះឈ្មោះជាមួយមន្ត្រីទំនាក់ទំនងខាងក្រោម ។

**ទំនាក់ទំនងខាងសារពត៌មានៈ ព្រិន្ទបាលឯក ស្ទីវ ប៊ឺក (Steve Bourke, DAA)**

**ជំនួយការរដ្ឋបាលសេនានុព័ន្ធ ទូរស័ព្ទលេខ ០១២ ៨០៤ ០៧១/០២៣ ២១៣ ៤៧០**

**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩**